# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបពិភាក្សាការងារជាមួយ

# ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន



នៅព្រឹកថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៤ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម **Toshimitsu Motegi** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន នៅទីស្តីការក្រសួង ។





ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសម្តែងនូវការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហការដ៏ល្អរវាងកម្ពុជា-ជប៉ុន ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម ។ ឯកឧត្តម បានចាត់ទុកដំណើរទស្សនៈកិច្ចរបស់ឯកឧត្តម រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច-ពាណិជ្ជកម្ម និងឧស្សាហកម្ម ជប៉ុន ដែលអមដំណើរដោយប្រតិភូវិស័យឯកជន ជាពិសេសក្រុមហ៊ុនជប៉ុន ដែលកំពុងប្រតិបត្តិការវិនិយោគនៅកម្ពុជាផងដែរ នោះ នឹងពង្រឹងពង្រីកបានថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ ដើម្បីផលប្រយោជន៍រួម ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសម្តែងការរីករាយ និងអបអរសាទរ ដែលថ្មីៗនេះ ក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម ជប៉ុន ទើបបានបោះពុម្ពចេញនូវសៀវភៅស ស្តីអំពីសហគ្រាសខ្នាតតូច និងមធ្យម ដែលសង្ឃឹមថា កម្ពុជា ជាពិសេសក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលកំពុងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍន៍ និងការគ្រប់គ្រងសហគ្រាសខ្នាតតូច និងមធ្យម នឹងយកជាមូលដ្ឋានបទពិសោធន៍ និងសិក្សាស្វែងយល់ ក្នុងន័យជួយជម្រុញវិស័យសហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា ដែលមានជាង៥ សែនមូលដ្ឋាន អាចមានលទ្ធភាពពង្រឹងខ្លួន និងឧត្តមភាពប្រកួតប្រជែង ក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលនឹងលេចចេញជារូបរៀង នៅឆ្នាំ២០១៥ ខាងមុខនេះ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើថា បើសៀវភៅសនោះ បកប្រែជាភាសាអង់គ្លេស ជាការប្រសើរសម្រាប់កម្ពុជា និងបានស្នើផងដែរឱ្យក្រសួងសេដ្ឋកិច្ចពាណិជ្ជកម្ម និងឧស្សាហកម្មជប៉ុនពិនិត្យលទ្ធភាព ជួយកម្ពុជា ផ្នែកការចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក (Online) នៃសហគ្រាសខ្នាតតូច និងមធ្យម ពីព្រោះ ប្រទេសជប៉ុនមានបទពិសោធន៍លើការងារនេះ ដែលអាចគ្រប់គ្រងរហូតដល់ជាង៩លានសហគ្រាសខ្នាតតូច និងមធ្យម ទូទាំងប្រទេសជប៉ុន ។ ចំណែកកម្ពុជា ក្នុងចំណោម ៥សែន មូលដ្ឋាន ទើបចុះបញ្ជីបាន ៣ម៉ឺនមូលដ្ឋានប៉ុណ្ណោះ ។

ឯកឧត្តម **Toshimitsu Motegi** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម នៃប្រទេសជប៉ុន បានសម្តែងការរីករាយចំពោះការបំពេញទស្សនៈកិច្ចជាផ្លូវការនៅកម្ពុជា ជាប្រទេស ដែលមានអារិយធម៌ និងវប្បធម៌រុងរឿង

និងកំពុងមានសក្តានុពលផ្នែកសេដ្ឋកិច្ច ដែលធ្វើឱ្យអ្នកវិនិយោគជប៉ុនកំពុងចាប់អារម្មណ៍បណ្តាក់ទុននៅកម្ពុជា ជាបន្តបន្ទាប់។ ទាក់ទងនិងការជម្រុញអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម ឯកឧត្តមរដ្ឋមន្ត្រី ជប៉ុន បានប្រកាសនូវគម្រោងកម្មវិធីមួយ ដែលយកឈ្មោះ ឯកឧត្តមផ្ទាល់ គឺ : **"Management &Operation Training for Economic Development &Global Industry Programme"** ដែលគម្រោងកម្មវិធីនេះនឹងជួយបើកវគ្គបណ្តុះបណ្តាលថ្នាក់បឋម និងថ្នាក់គ្រប់គ្រងដល់សហគ្រាសក្នុងស្រុកកម្ពុជាចំនួន៥0 និងផ្តល់ឱកាសឱ្យសហគ្រិនវ័យក្មេងជប៉ុនមកធ្វើកម្មសិក្សា នៅកម្ពុជា ដើម្បីផ្លាស់ប្តូរបទពិសោធន៍ជាមួយដៃគូកម្ពុជា ។ ជាមួយគ្នានេះ ក្រសួងក៏មានកម្មវិធីមួយទៀត ហៅថា វេទិកាជួយសហគ្រាសខ្នាតតូច និងមធ្យម ដែលធ្វើអាជីវកម្មនៅក្រៅប្រទេស ឱ្យមានលទ្ធភាពពង្រីកអាជីវកម្មរបស់ខ្លួន ។ គម្រោងកម្មវិធីនេះ គឺជួយដល់សហគ្រាសខ្នាតតូច និងមធ្យម នៅតំបន់អាស៊ាន ដោយយករបាយការណ៍វាយតម្លៃរបស់វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ារបស់ជប៉ុន (ERIA)ជាមូលដ្ឋានផងដែរ ។

ជាមួយនឹងការបង្ហាញនូវការទទួលយកចំពោះសំណើររបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ខាងលើ ស្តីពីការគ្រប់គ្រងការចុះបញ្ជី ក៏ដូចជាការអភិវឌ្ឍន៍សហគ្រាសខ្នាតតូច និងមធ្យម នៅកម្ពុជា ឯកឧត្តម រដ្ឋមន្ត្រី **Toshimitsu Motegi** ក៏បានបង្ហាញនូវកង្វល់មួយចំនួន ដែលក្រុមហ៊ុនវិនិយោគជប៉ុននៅកម្ពុជាជួបប្រទះ គឺ **ទី១:**ថ្លៃអគ្គិសនីខ្ពស់ **ទី២:** ភាពស្មុគស្មាញខ្លះនីតិវិធីគយ បើទោះបីកម្ពុជាមានកំណែទម្រង់ច្រើនហើយក៏ដោយ និងទី៣:និន្នាការលឿនពេកនៃការតវ៉ាតម្លើងប្រាក់ខែគោលរបស់កម្មករ ។

ជាការឆ្លើយតប ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកឡើងពីការខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់ខ្លួន ។ ទាក់ទងនិងថ្លៃអគ្គិសនី ឯកឧត្តម បានបញ្ជាក់ថា:រាជរដ្ឋាភិបាលបានខិតខំទាក់ទាញការវិនិយោគឱ្យបានច្រើន ផ្នែកអភិវឌ្ឍន៍វារីអគ្គិសនី-អគ្គិសនី ដើរដោយធ្យូងថ្ម និងការជាវអគ្គិសនីពីប្រទេសជិតខាងជាដើម ។ ទាំងអស់នេះ យើងនឹងអាចដោះស្រាយបាន ជាបណ្តើរៗចំពោះភាពប្រឈម ហើយសង្ឃឹមថា:ក្រសួងរ៉ែ និងថាមពលដែលជាក្រសួងជំនាញនឹងសម្រួលកិច្ចការនេះបានប្រសើរសម្រាប់ក្រុមហ៊ុនរោងចក្រដែលមានតម្រូវការអគ្គិសនីដ៏ច្រើន ។ ទាក់ទង និងនីតិវិធីគយ ឯកឧត្តម បានបញ្ជាក់ថា:រដ្ឋាភិបាលបានធ្វើកំណែទម្រង់ជាច្រើន បើតាមដឹងចំពោះប្រព័ន្ធស្វ័យប្រវត្តិកម្មនៃទិន្នន័យគយ ហៅកាត់ថា: ASYCUDA នោះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ បានអនុវត្តដល់ដំណាក់កាលទី៤ ហើយ ហើយកំពុងធ្វើបច្ចុប្បន្នភាពបន្ថែមទៀត ។ ទាក់ទងនិងនិន្នាការនៃការតវ៉ាតម្លើងប្រាក់ខែគោល របស់កម្មកររោងចក្រ ឯកឧត្តម ទេសរដ្ឋមន្ត្រី ក៏បានសម្តែងនូវកង្វល់ផងដែរ ពីព្រោះវាប៉ះពាល់ដល់ផែនការអភិវឌ្ឍន៍របស់ក្រុមហ៊ុន ។ តែទោះជាយ៉ាងណា រាជរដ្ឋាភិបាលកំពុងមានការគិតគូថ្លឹងថ្លែងយ៉ាងយកចិត្តទុកដាក់ ហើយក៏មានគណៈកម្មការចម្រុះកំពុងពិភាក្សាដោះស្រាយរកចំណុចរួមផងដែរ ។